GC LiFE

# អត្ថប្រយោជន៍លើការព្យាបាល
# ជំងឺធ្ងន់ធ្ងរ



## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 18 - 60ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 5 - 30ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000ឡើង |

## អត្ថប្រយោជន៍ធានារ៉ាប់រង

**ជំងឺធ្ងន់ធ្ងរកម្រិតដំបូង***

**25%** នៃទឹកប្រាក់ត្រូវបានធានា
(អតិបរមា $25,000)

**ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់***

**100%** នៃទឹកប្រាក់ត្រូវបានធានា
(ដោយដកនូវសំណងសម្រាប់ជំងឺធ្ងន់ធ្ងរកម្រិតដំបូង ប្រសិនបើមាន)

*រយៈពេលរស់រានមានជីវិត និងរយៈពេលរង់ចាំត្រូវបានអនុវត្ត!

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

| | ជំងឺធ្ងន់ធ្ងរកម្រិតដំបូង | ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ |
|---|---|---|
| ខួរក្បាល | -ការដាក់បញ្ចូលឧបករណ៍បង្ហូរទឹកស្រោបខួរ<br>-ការសន្លប់បាត់ស្មារតីដែលបន្តរហូត >=៤៨ម៉ោង | -ជំងឺដាច់សរសៃឈាមខួរក្បាល<br>-ការសន្លប់បាត់ស្មារតីដែលបន្តរហូត >=៩៦ម៉ោង<br>-ជំងឺវង្វេងវង្វាន់ (បាត់ការចងចាំ)<br>-ជំងឺប៉ាគីនសុន |
| បេះដូង | -ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬ ការដាក់បញ្ចូលម៉ាស៊ីនភ្ញោចបេះដូង<br>-ការព្យាបាលសរសៃឈាមបេះដូងដោយប្រើឧបករណ៍តាមសរសៃឈាម<br>-ការវះកាត់ប្រឹសបេះដូងដោយប្រើឧបករណ៍តាមសរសៃឈាម<br>-ការវះកាត់ពង្រីកប្រឹសបេះដូង | -ជំងឺគាំងបេះដូង<br>-ការវះកាត់សរសៃឈាមបេះដូងដែលឆ្លងកាត់កន្លែងដែលស្ទះ<br>-ការវះកាត់ប្រឹសបេះដូងដោយវះបើកទ្រូង<br>-ការវះកាត់ផ្សាំបេះដូង |
| សួត | -ការវះកាត់យកសួតមួយចំហៀងចេញ | -ជំងឺសួតដំណាក់កាលចុងក្រោយ<br>-ការវះកាត់ផ្សាំសួត |
| ថ្លើម | -ការវះកាត់ផ្នែកខ្លះនៃថ្លើម | -ការខូចថ្លើមដំណាក់កាលចុងក្រោយ<br>-ការវះកាត់ផ្សាំថ្លើម |
| តម្រងនោម | -ការវះកាត់យកតម្រងនោមមួយចំហៀងចេញ | -ការខូចតម្រងនោមដំណាក់កាលចុងក្រោយ<br>-ការវះកាត់ផ្សាំតម្រងនោម |
| ពោះវៀនតូច | -ការវះកាត់ផ្សាំពោះវៀនតូច | |
| លំពែង | | -ការវះកាត់ផ្សាំលំពែង |
| ជំងឺមហារីក | -ដាលិកាមហារីកនៅទីតាំងដើម (CIS)<br>-មហារីកក្រពេញប្រូស្តាតដំណាក់កាលដំបូង<br>-មហារីកក្រពេញទីរ៉ូអ៊ីតដំណាក់កាលដំបូង<br>-មហារីកប្លោកនោមដំណាក់កាលដំបូង<br>-ជំងឺមហារីកគោលិកាសឡាំផូស៊ីតរ៉ាំរ៉ៃដំណាក់កាលដំបូង | -ជំងឺមហារីកដំណាក់កាលធ្ងន់ធ្ងរ |
| ឈាម | | -ជំងឺខ្វះឈាមក្រហមដោយការខូចខួរឆ្អឹង |
| ផ្សេងៗ | -ការរលាកកម្រិតទី ២ | -ការរលាកកម្រិតទី ៣ |

## ករណីមិនធានា

ធានារ៉ាប់រងបន្ថែមនេះមិនធានាលើ៖
១. ជំងឺដែលបណ្តាលមកពីជំងឺអេដស៍ ភាពស្មុគស្មាញទាក់ទងនឹងជំងឺអេដស៍ ឬការបង្ករោគដោយវីរុសហ៊ីវ (HIV)។
២. ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

(១) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល

(២) យោបល់វេជ្ជសាស្រ្ត ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្រ្តត្រូវបានណែនាំ

(៣) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

(៤) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

៣. ការប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
៤. អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។
៥. ជំងឺធ្ងន់ធ្ងរទាំងអស់ដែលមានស្រាប់ ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយ រាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូង ដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំ ហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។
៦. សង្គ្រាម ឬសកម្មភាពពាក់ព័ន្ធនឹងសង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការធ្វើកូដកម្ម ចលនាបះបោរ បដិវត្តន៍ សង្គ្រាមស៊ីវិល សកម្មភាពភេរវកម្មមិនថាអ្នកត្រូវបានធានារ៉ាប់រងចូលរួម ឬមិនចូលរួមក្តី។
៧. ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល។ អ្នកទទួលផលដែលមិនបានចូលរួមពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសព្រហ្មទណ្ឌ ដែលបានរៀបរាប់ខាងលើនឹងនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍របស់ពួកគេដដែល។
៨. ប្រសិនបើមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីការសារធាតុវិទ្យុសកម្មដែលកើតឡើងពី ឥន្ធនៈ អាវុធ កាកសំណល់ ឬការកែច្នៃ។
៩. ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយដែលធ្វើការជាប្រចាំ និងទៀងទាត់តាមកាលវិភាគ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។
១០. ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។